# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីលោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 22-Nov-2011, 14:14
CMS/CFO: Kauv Keoratanak

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះ

អាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## បណ្តឹងជំទាស់ជាបន្ទាន់ចំពោះចៅក្រម CARTWRIGHT

---

__ដាក់ដោយ៖__

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ

Michiel PESTMAN
Victor KOPPE
Andrew IANUZZI
Jasper PAUW

ព្រុំ ផល្លា

Zara LOCKSHIN
Mojan SAMADI

__ផ្ញើជូន៖__

**សហជនជាប់ចោទ**

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**សហមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី**

PICH Ang

Elisabeth SIMONNEAU-FORT

## I. សេចក្តីផ្តើម

១. អនុលោមតាមមាត្រា ៥៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងមាត្រា ៣៤ នៃវិធានផ្ទៃក្នុងរបស់ អវតក ("វិធានផ្ទៃក្នុង") មេធាវីការពារក្តីជនជាប់ចោទ នួន ជា ("ក្រុមមេធាវីការពារក្តី") ដាក់បណ្តឹងជំទាស់នេះចំពោះចៅក្រម Silvia Cartwright ពីដំណើរការនីតិវិធីទាំងអស់នៅក្នុងករណី ០០២ ។ សម្រាប់មូលហេតុទាំងអស់ដែលបញ្ជាក់នៅខាងក្រោម ក្រុមមេធាវីការពារក្តីស្នើឲ្យពិចារណាថា: (i) បណ្តឹងជំទាស់នេះ គឺអាចទទួលយកបាន, (ii) ចៅក្រម Cartwright ត្រូវតែ (ឬយ៉ាងហោចណាស់ គប្បី) លាលែងដោយរង់ចាំដំណោះស្រាយលើបណ្តឹងជំទាស់នេះ និង(iii) ការជាប់ពាក់ព័ន្ធរបស់លោកស្រីជាមួយសហព្រះរាជអាជ្ញាអន្តរជាតិ និង/ឬអនុប្រធានការិយាល័យរដ្ឋបាលនៅក្នុងបរិបទនៃកិច្ចប្រជុំក្រៅផ្លូវការតែជាមួយ*ភាគីម្ខាង* ("កិច្ចប្រជុំ") អាចនាំឲ្យអ្នកអង្កេតការមិនលំអៀង និងដែលត្រូវបានជូនដំណឹងយ៉ាងត្រឹមត្រូវ មើលឃើញពីភាពលំអៀងរបស់លោកស្រី ។ ដោយពិចារណាពីសារៈសំខាន់ផ្នែកច្បាប់ដែលបានលើកឡើងនៅទីនេះ និងផលប្រយោជន៍ទូទៅនៅក្នុងដំណើរការនីតិវិធីជំនុំជម្រះ បណ្តឹងជំទាស់នេះត្រូវតែបានចំណាត់ថ្នាក់ជាសាធារណៈ[1] ។ ទោះជាក្នុងកាលៈទេសៈណាក៏ដោយក្រុមមេធាវីការពារក្តីចាត់ទុកបណ្តឹងជំទាស់នេះជាសាធារណៈ ។

## II. អង្គហេតុពាក់ព័ន្ធ

២. ដើម្បីរក្សាឲ្យខ្លី ក្រុមមេធាវីការពារក្តីសូមដាក់បញ្ចូលសេចក្តីសន្និដ្ឋានអង្គហេតុទាំងអស់ដែលមានចែងនៅកថាខណ្ឌទី៣ រហូតដល់កថាខណ្ឌទី១២ នៃសំណើរបស់ អៀង សារី សុំឲ្យមានការស៊ើបអង្កេតការប្រាស្រ័យទាក់ទងតែភាគីម្ខាងរវាងសហព្រះរាជអាជ្ញាអន្តរជាតិ ចៅក្រម Cartwright និងអ្នកផ្សេង" ("សំណើរបស់ អៀង សារី") ។ ដោយសារសំណើនេះមិនទាន់ដាក់ក្នុងសំណុំរឿង សំណៅនៃសំណើនេះត្រូវបានដាក់ភ្ជាប់មកជាមួយ[2] ។ បន្ថែមពីលើនេះ ក្រុមមេ

---

[1] សូមមើលកថាខណ្ឌទី ខាងក្រោម ។

[2] កំណត់សំគាល់៖ សំណៅចម្លងនៃសំណើសុំដែលដាក់ក្នុងលក្ខណៈឃោគយល់ ត្រូវបានផ្តល់ឲ្យភាគីនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១១ ។

ធាវីការពារក្តី សូមដាក់បញ្ចូលទាំងស្រុងនៃសំណើនានារបស់ខ្លួនដែលបានដាក់កាលពីលើកមុន នៅអង្គជំនុំជម្រះសាលាដំបូង សុំព័ត៌មានទាក់ទងនឹងកិច្ចប្រជុំទាំងនេះ[3] ។ ជាចុងក្រោយ សូមសង្កត់បញ្ជាក់ថាក្នុងអំឡុងពេលដែលកិច្ចប្រជុំតែភាគីម្ខាងបានកើតឡើង អង្គជំនុំជម្រះបានទទួលញត្តិមួយដែលដាក់ដោយក្រុមមេធាវីការពារក្តី ស្នើសុំឱ្យមានការស៊ើបអង្កេតអនុភាពនៃការជ្រៀតជ្រែកខាងនយោបាយសំណាក់រាជរដ្ឋាភិបាលកម្ពុជានៅក្នុងករណី ០០២[4] ។ ការិយាល័យរបស់លោក Andrew Cayley ជំទាស់សំណើនោះ[5] ហើយចៅក្រម Cartwright និងសហសេវិនរបស់គាត់នៅអង្គជំនុំជម្រះសាលាដំបូង បានសម្រេចជាឯកច្ឆ័ន្ទដោយបានបដិសេធលើសំណើនេះ[6] ។

## III. ច្បាប់ដែលពាក់ព័ន្ធ

### ក.អនាគតិតុលាការ

៣. មាត្រា ១២៨ នៃរដ្ឋធម្មនុញ្ញកម្ពុជាតម្រូវឱ្យតុលាការមិនលម្អៀង៖ “អំណាចតុលាការធានារក្សាអនាគតិ និងការពារសិទ្ធិ សេរីភាពរបស់ប្រជាពលរដ្ឋ” ។ ទស្សនទានដ៏សំខាន់នេះមានចែងនៅក្នុងកិច្ចព្រមព្រៀង និងច្បាប់បង្កើត អវតក ដែលចែងថាចៅក្រម “ត្រូវតែជាបុគ្គល

---

[3] សូមមើលឯកសារ E-137 លិខិតពីក្រុមមេធាវីការពារ នួន ជា ជូនចៅក្រម និល ណុន កម្មវត្ថុ: សំណើសុំព័ត៌មានទាក់ទងនឹងកិច្ចប្រជុំតែភាគីម្ខាងរវាងចៅក្រម Cartwright, លោក Andrew Cayley និងលោក Knut Rosandaug ” ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១១ ERN 00752773 ។ ឯកសារ E-137/1 “សំណើសុំព័ត៌មានទាក់ទងនឹងកិច្ចប្រជុំតែភាគីម្ខាងក្នុងចំណោមចៅក្រម Cartwright, សហព្រះរាជអាជ្ញាអន្តរជាតិ Andrew Cayley និងអនុប្រធានការិយាល័យរដ្ឋបាល លោក Knut Rosandaug ” ERN 00753050–00753053 ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១១ (“សំណើ នួន ជា”) ។

[4] សូមមើលឯកសារ E-82 “សំណើកិច្ចស៊ើបសួរអនុលោមតាមវិធាន ៣៥” ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១១ ERN 00680941–00680955

[5] សូមមើលឯកសារ E-82/1 “ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ នួន ជា សុំឱ្យមានកិច្ចស៊ើបសួរអនុលោមតាមវិធាន ៣៥” ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១១ ERN 00686305–00686308 ។

[6] សូមមើលឯកសារ E-116 “សេចក្តីសម្រេចលើញត្តិរបស់ នួន ជា ទាក់ទងនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (E51/3, E82, E88, and E92)’ ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១១ ERN 00729330–00729339 ។ សូមមើលផងដែរឯកសារ **E-116/1**, “បណ្តឹងឧទ្ធរណ៍ជាបន្ទាន់ប្រឆាំងនឹងដីកាសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១ ERN 00746636–00746658 ។

ដែលមានចរិតលក្ខណៈ និងស្មារតីខ្ពស់ មិនលំអៀង និងសុចរិត និងមានគុណសម្បត្តិ”[7]។ ការធានាដូចគ្នានេះ មានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស និងសិទ្ធិនយោបាយ (‘ICCPR’)[8] អនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (ECHR)[9] អនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស[10] ធម្មនុញ្ញអាហ្វ្រិកស្តីពីមនុស្ស និងសិទ្ធិមនុស្ស[11] ព្រមទាំងលក្ខន្តិកៈរបស់តុលាការ ICC[12] តុលាការ ICTR[13] និងតុលាការ ICTY[14]។ ជាការពិតគណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ បានលើកឡើងថាការធានាចំពោះអនាគតិ *“គឺជាសិទ្ធិដាច់ខាតដែលមិនអាចលើក*

---

[7] មាត្រា ៣(៣) នៃកិច្ចព្រមព្រៀង អវតក ។ សូមមើលផងដែរមាត្រា ១០ថ្មី នៃច្បាប់បង្កើត អវតក (“ចៅក្រមនៅអង្គជំនុំជម្រះ... មានចរិតលក្ខណៈ និងស្មារតីខ្ពស់ មិនលំអៀង និងសុចរិត [...].) ។

[8] មាត្រា ១៤(១) (“ជនគ្រប់រូប មានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងជាសាធារណៈដោយតុលាការមានសមត្ថភាពមាន និង ឥតលំលៀង ដែលបង្កើតឡើងដោយច្បាប់”) ។

[9] មាត្រា ៦(១) “ជនគ្រប់រូបមានសិទ្ធិ មានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងជាសាធារណៈក្នុងពេលវេលាសមស្របដោ យតុលាការមានសមត្ថភាពមាន និង ឥតលំលៀងដែលបង្កើតឡើងដោយច្បាប់”) ។

[10] មាត្រា ៨(១) “ជនគ្រប់រូបមានសិទ្ធិទទួលបានជំនុំជម្រះ ដោយមានការធានាតាមច្បាប់ និងក្នុងពេលវេលាសមស្របដោយតុលាការមានសមត្ថភាព, ឯករាជ្យ និងឥតលំអៀង ។

[11] មាត្រា ៧(១) ““ជនគ្រប់រូបមានសិទ្ធិទទួលបានការជំនុំជម្រះលើបុព្វហេតុរបស់ខ្លួន ។ សិទ្ធិនេះរួមបញ្ចូលទាំង [...] (ឃ) សិទ្ធិត្រូវកាត់សេចក្តីក្នុងពេលវេលាសមស្របដោយតុលាការឯករាជ្យ និងឥតលំអៀង ។ សូមមើលឧទាហរណ៍គំរោងសិទ្ធិតទល់ជាមួយប្រទេសនីហ្សេរី, គណៈកម្មាធិការសិទ្ធិមនុស្ស និងសិទ្ធិប្រជាជនអាហ្វ្រិក សំណុំរឿង ៨៧/៩៣)(១៩៩៥) សេចក្តីសម្រេចនៅកថាខណ្ឌទី១៤ (ដោយមិនគិតដល់ចរិតលក្ខណៈរបស់សមាជិករបស់តុលាការ គ្រាន់តែសមាភាពរបស់វាប៉ុណ្ណោះ បង្កើតឲ្យឃើញនូវភាពអនាគតិរួចហើយ ។ ដូច្នេះវារំលោភមាត្រា ៧.១(ឃ) ។

[12] មាត្រា៦៧(១) (ធាតុផ្សំទូទៅ) (‘ក្នុងការកំណត់បទចោទប្រកាន់ណាមួយ ជនជាប់ចោទត្រូវមានសិទ្ធិទទួលបាន […] ការជំនុំជម្រះដោយយុត្តិធម៌ និងដោយឥតលម្អៀង […])

[13] មាត្រា១៣ (“ចៅក្រមអាសនៈ និងចៅក្រម *បម្រុង* ជាបុគ្គលមានសីលធម៌ខ្ពស់ មិនលម្អៀង និងសុចរិតដែលមានលក្ខណៈសម្បត្តិ ដែលជាលក្ខខណ្ឌតម្រូវនៅក្នុងប្រទេសរៀងៗខ្លួនសម្រាប់ការតែងតាំងជាតំណែងចៅក្រមខ្ពស់បំផុត) ។

[14] មាត្រា១២(១) (‘ចៅក្រមអាសនៈ និងចៅក្រមបំរុងត្រូវជាបុគ្គលមានសីលធម៌ខ្ពស់ មិនលម្អៀង និងសុចរិត ដែលមានលក្ខណៈសម្បត្តិតម្រូវនៅក្នុងប្រទេសរៀងៗខ្លួនសម្រាប់ការតែងតាំងជាតំណែងចៅក្រមខ្ពស់បំផុត។’)

*ឡើងឡើយ*"[15]។ ដូចដែលបានសម្រេចដោយតុលាការអឺរ៉ុបសិទ្ធិមនុស្ស: "អ្វីដែលជាការព្រួយបារម្ភនោះ គឺទំនុកចិត្តដែលតុលាការទាំងឡាយនៅក្នុងសង្គមប្រជាធិបតេយ្យត្រូវតែជំរុញឱ្យសាធារណៈជនមានជឿទុកចិត្ត"[16]។ អង្គជំនុំជម្រះនេះបានសម្តែងនូវមនោសញ្ចេតនានេះជាបន្តបន្ទាប់ "ការធានារក្សាឯករាជ្យភាពតុលាការ គឺមានសារៈសំខាន់ជាទីបំផុត និងជាចំណុចស្នូលដល់ទំនុកចិត្តរបស់សាធារណៈនៅក្នុងតុលាការ"[17]។

## ខ. ការដកខ្លួន និង បណ្តឹងជំទាស់ចៅក្រម

៤. វិធាន ៣៤ នៃវិធានផ្ទៃក្នុង ដោះស្រាយលើ "ការដកខ្លួននិងការប្តឹងជំទាស់ចៅក្រម" ចែងត្រង់ផ្នែកដែលពាក់ព័ន្ធថា៖

> ភាគីអាចធ្វើបណ្តឹងជំទាស់ចៅក្រមចំពោះសហចៅក្រមស៊ើបអង្កេត ឬ ចៅក្រមនៃអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង ឬ អង្គជំនុំជម្រះតុលាការកំពូល ក្នុងករណីណាមួយ [...] ដែលចៅក្រមរូបនោះមាន ឬ ធ្លាប់មានការពាក់ព័ន្ធ ដែលអាចធ្វើឱ្យប៉ះពាល់យ៉ាងពិតប្រាកដដល់ភាពអនាគតិរបស់ចៅក្រមរូបនោះ ឬ អាចបង្កើតឱ្យមានភាពលម្អៀង[18]។

---

[15] *រឿងក្តី* Gonzalez del Rio *តទល់នឹង* Peru, លិខិតឆ្លើយឆ្លងលេខ 263/1987, ឯកសារ អ.ស.ប CCPR/C/46/D/263/1987, ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩២ (គូសបញ្ជាក់បន្ថែម)។

[16] *រឿងក្តី* Ferrantelli *និង* Santangelo *តទល់នឹង* Italy, ECtHR App Nos 48/1995 & 554/640, 'សាលក្រម', ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ១៩៩៦ ('សាលក្រម Ferrantelli'), កថាខណ្ឌ៥៨។

[17] ឯកសារ E-5/3 "សេចក្តីសម្រេចលើសំណើរបស់ អៀង សារី សុំជំទាស់ចៅក្រម និល ណុន និងសំណើដែលពាក់ព័ន្ធនានា ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១ ERN 00640427–00640435 (ពាក្យបណ្តឹងជំទាស់ចំពោះចៅក្រម និល ណុន) កថាខណ្ឌ ១១ ។ សូមមើលផងដែរនៅកថាខណ្ឌទី៥ នៃបណ្តឹងជំទាស់ខាងលើ ("សិទ្ធិទទួលបានការជំនុំជម្រះដោយតុលាការមួយមិនលម្អៀង និងឯករាជ្យ គឺជាធាតុផ្សំសំខាន់នៃសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌") ។ កថាខណ្ឌទី១១ ("ដូចដែលបានកត់សំគាល់ គោលបំណងរបស់បទប្បញ្ញត្តិស្តីពីការដកចៅក្រម និងជំទាស់ចៅក្រម គឺដើម្បីធានាអនាគតិរបស់ចៅក្រមនៅក្នុងករណីជាក់លាក់") ។ កថាខណ្ឌទី១៤ ("ខណៈជាតុលាការគំរូ តុលាការនេះអាចលើកកំពស់ការធានានូវឯករាជ្យភាព និងសុចរិតភាពរបស់តុលាការ") ។

[18] វិធាន៣៤(២) (គូសបញ្ជាក់បន្ថែម)។

ភាគីដាក់ពាក្យប្តឹងជំទាស់ ‘ត្រូវបង្ហាញឲ្យច្បាស់លាស់អំពីមូលហេតុនៃការប្តឹងជំទាស់ និងត្រូវមានភស្តុតាងបញ្ជាក់ផងដែរ’[19] និងពាក្យបណ្តឹងត្រូវធ្វើឡើងឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន នៅពេលណាដែលភាគីបានដឹងអំពីមូលហេតុនោះ’[20]។ ពាក្យប្តឹងជំទាស់ប្រឆាំងនឹងចៅក្រមរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងបញ្ហាក្នុងអំឡុងពេលជំនុំជម្រះ ត្រូវដាក់ជូន “នៅមុនពេលធ្វើសេចក្តីសម្រេចចុងក្រោយលើសំណុំរឿងនោះ”[21] ។ នៅក្នុងករណីបែបនេះបណ្តឹងត្រូវដាក់ប្តឹងឲ្យបានត្រឹមត្រូវនៅអង្គជំនុំជម្រះសាលាដំបូងខ្លួនឯង[22]។ បទបញ្ញត្តិនេះស្របទៅនឹងច្បាប់ជាធរមានរបស់កម្ពុជា ពោលគឺក្រមនីតិវិធីព្រហ្មទណ្ឌ[23]។

៥. ការដកចេញយ៉ាងច្បាស់លាស់ និងមិនសមហេតុផលពីច្បាប់ជាតិ[24] វិធាន៣៤(៥)ចែងថា នៅពេលដាក់បណ្តឹងជំទាស់នោះហើយ ‘ចៅក្រមដែលកំពុងមានបញ្ហាអាចបន្តចូលរួមនៅក្នុង

---

[19] វិធាន៣៤(៣)។

[20] *ដូចជើងទំព័រខាងលើ*។

[21] វិធាន ៣៤(៤)(ក)។

[22] *សូមមើល* វិធាន៣៤(៥) (‘ពាក្យបណ្តឹងជំទាស់ចំពោះសហចៅក្រមស៊ើបអង្កេត ត្រូវដាក់ជូនទៅអង្គបុរេជំនុំជម្រះ ។ ក្នុងករណីផ្សេងទៀត ពាក្យបណ្តឹងជំទាស់ត្រូវដាក់ជូនទៅអង្គជំនុំជម្រះណាមួយ ដែលចៅក្រមនោះស្ថិតនៅ ។ [...]។’)

[23] សូមមើលឧទាហរណ៍ មាត្រា ៥៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា (“ភាគីដែលចង់ប្តឹងជំទាស់ចៅក្រមមានអាសនៈណាមួយ ត្រូវតែជូនពាក្យប្តឹងតាំងពីពេលខ្លួនបានដឹងពីមូលហេតុនៃការប្តឹងជំទាស់ បើពុំដូច្នេះទេ មិនអាចទទួលយកបានឡើយ ។ ក្នុងករណីណាក៏ដោយ ពាក្យប្តឹងជំទាស់ចៅក្រមនោះមិនអាចធ្វើបានឡើយ នៅពេលបិទពិភាក្សាដេញដោល ។ មាត្រា ៥៥៨ នៃច្បាប់នេះ (“ភាគីដែលចង់ប្តឹងជំទាស់ចៅក្រមត្រូវតែចង្អុលបង្ហាញឲ្យបានច្បាស់លាស់អំពីមូលហេតុនៃការប្តឹងជំទាស់ ហើយត្រូវមានភស្តុតាងបញ្ជាក់ច្បាស់លាស់ បើមិនដូច្នេះទេពាក្យប្តឹងនេះពុំអាចទទួលយកបានឡើយ ។

[24] កំណត់សំគាល់៖ មេធាវីការពារក្តីបានជំទាស់ជាបន្តបន្ទាប់ទៅនឹងការដកចេញពីនីតិវិធីដែលនៅជាធរមានរបស់កម្ពុជាដោយការយោងមិនសមហេតុផលទៅលើមាត្រា ១២(១)នៃកិច្ចព្រមព្រៀង អវតក ។ សូមមើលឧទាហរណ៍ ឯកសារ E-51/3 “អញ្ញត្រកម្មរួម” ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១១ ERN 00648279–00648310 ។ បើតាមមេធាវីការពារក្តីដឹងមិនមានការផ្តល់យុត្តិកម្មបែបនេះ តាមវិធាន ៣៤ ទេ ។ មេធាវីការពារក្តីមិនទទួលយកការបកស្រាយលើចំណុចនេះ ដោយអង្គជំនុំជម្រះឡើយ ។ សូមមើលឯកសារ E-51/14 “សេចក្តីសម្រេចលើអញ្ញត្រកម្មរបស់ នួន ជា ដែលលើកឡើងពីលក្ខណៈគ្មានធម្មនុញ្ញភាពនៃវិធានផ្ទៃក្នុងរបស់ អវតក” ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១១ ERN 00707531–00707535 ។ តែដោយសារការសេចក្តីជំទាស់នេះមិនអាចប្តឹងឧទ្ធរណ៍ភ្លាមៗបាន នោះមេធាវីការពារក្តីសូមបញ្ជាក់ឡើងវិញពីការជំទាស់របស់ខ្លួន

កិច្ចដំណើរការនីតិវិធី ដោយរង់ចាំសេចក្ដីសម្រេចលើបណ្ដឹងជំទាស់ចៅក្រម។ ប៉ុន្តែចៅក្រមនោះ[...] *អាចសម្រេចចិត្តលាលែងដោយស្ម័គ្រចិត្តបាន* នៅគ្រប់ពេលវេលាក្នុងដំណើរការនីតិវិធី'[២៥]។ នេះមិនស្របនឹងមាត្រា ៥៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលចែងថា "ចៅក្រមដែលត្រូវគេប្ដឹងជំទាស់ចិត្ត *ត្រូវដកខ្លួន* ចេញពីការស៊ើបអង្កេត ឬការជំនុំជម្រះ"[26]។ ទោះជាក្នុងករណីណាក៏ដោយទាំងវិធានក្នុងនិងក្រមនីតិវិធីព្រហ្មទណ្ឌចែងថា ចៅក្រមដែលត្រូវប្ដឹងដែលបានលាលែង បើទោះបីជាដោយស្ម័គ្រចិត្ត ឬដោយចាប់បង្ខំដោយច្បាប់ "ត្រូវតែជំនួស" សម្រាប់គោលបំណងនៃបណ្ដឹងជំទាស់ចិត្តនេះតែប៉ុណ្ណោះ'[27]។

៦. នៅពេលអនុវត្តវិធាន ៣៤ នៃវិធានផ្ទៃក្នុងនៅក្នុង អង្គជំនុំជម្រះសាលាដំបូងបានអនុម័តយកការវាយតម្លៃដែលបង្កើតឡើងជាលើកដំបូងដោយអង្គជំនុំជម្រះតុលាការកំពូលនៅ ICTY នៅក្នុងរឿងក្ដី Anto Furundžija[28]។ យោងតាមបទដ្ឋាននោះ ចៅក្រមម្នាក់នឹងត្រូវបានគេយល់ឃើញថាមិនមានភាពឯករាជ្យ និងភាពលម្អៀង (ហេតុដូច្នេះ អាចជាកម្មវត្ថុនៃការប្ដឹងជំទាស់ចិត្ត) បើសិនជាត្រូវគេមើលឃើញថាភាពលម្អៀងជាក់ស្ដែងបានកើតឡើង ឬ'មានការលេចឡើងនូវភាពលម្អៀងដែលមិនអាចទទួលយកបាន' ("ការវាយតម្លៃបែបសន្យានុម័ត)[29]។

---

[25] វិធាន៣៤(៥) នៃវិធានផ្ទៃក្នុង។

[26] បញ្ជាក់បន្ថែម ។

[27] វិធាន៣៤(៦) នៃវិធានផ្ទៃក្នុង ។ (កត់សំគាល់ថាបើសិនចៅក្រមដែលរងការប្ដឹងជំទាស់ចិត្តលាលែង ចៅក្រមរូបនោះត្រូវតែដាក់ជំនួសនៅក្នុងអង្គជំនុំជម្រះ ដោយចៅក្រមបម្រុងម្នាក់ សម្រាប់គោលបំណងនៃបណ្ដឹងជំទាស់ចិត្តតែប៉ុណ្ណោះ) ។ មាត្រា ៥៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា (បង្ហាញថាចៅក្រមដែលរងការប្ដឹងជំទាស់ចិត្ត ត្រូវតែជំនួសដោយចៅក្រម ម្នាក់ទៀត ដែលត្រូវតែចាត់តាំងដោយប្រធានតុលាការរបស់ខ្លួន ។

[28] *សូមមើល* 'សេចក្ដីសម្រេចលើបណ្ដឹងជំទាស់ចិត្តចំពោះចៅក្រម និល ណុន នៅកថាខណ្ឌទី៦ (លើកមកសំអាងសេចក្ដីសម្រេច *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Furundžija*, IT-95-17/1-A, 'សេចក្ដីសម្រេច ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២000 ('សេចក្ដីសម្រេច Furundžija') ព្រមទាំងយុត្តិសាស្ត្រលើកមុនៗរបស់ អវតក និងយុត្តិ សាស្ត្រអន្តរជាតិដទៃទៀត ។

[29] សូមមើលឯកសារ **E-55/4** សេចក្ដីសម្រេចលើពាក្យប្ដឹងជំទាស់ចិត្តរបស់ អៀង ធីរិទ្ធ នួន ជា និង អៀង សារី ប្រឆាំងចៅក្រម និល ណុន, ចៅក្រម Silvia Cartwright, ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc Lavergne, និងចៅក្រម ធូ មរណី ចុះថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០១១ ERN 00655691–00655700 ។ (អត្ថបទពេញនៃសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង") នៅកថាខណ្ឌ ១១ (យុត្តិសាស្ត្ររបស់ អវតកក និងតុលាការព្រហ្មទណ្ឌអន្តរជាតិ

៧. ការវាយតម្លៃជាសត្យានុម័ត ត្រូវបានបំពេញក្នុងករណីដែលកាលៈទេសៈដែលនាំឱ្យអ្នកអង្កេតការឥតលម្អៀងដែលទទួលបានព័ត៌មានត្រឹមត្រូវ យល់ឃើញយ៉ាងត្រឹមត្រូវពីការលម្អៀង”[30]។ អ្នកអង្កេតការឥតលម្អៀង ត្រូវតែជា“បុគ្គលម្នាក់ដែលទទួលបានព័ត៌មានគ្រប់គ្រាន់ជាមួយនឹងការយល់ដឹងគ្រប់កាលៈទេសៈពាក់ព័ន្ធទាំងអស់ រាប់បញ្ចូលទាំងប្រពៃណីនៃសុចរិតភាព និងភាពមិនលម្អៀង ដែលបង្កើតបានជាផ្នែកមួយនៃសារតារ និងអង្គហេតុដែលថាភាពមិនលម្អៀងគឺជាករណីយកិច្ចមួយក្នុងចំណោមករណីកិច្ចផ្សេងៗដែលចៅក្រមគ្រប់រូបត្រូវតែប្រកាន់ភ្ជាប់”[31]។ ម៉្យាងវិញទៀត ដូចបានបញ្ជាក់ដោយអង្គជំនុំជម្រះពិសេសនៃតុលាការ ICTY៖ “អង្គជំនុំជម្រះត្រូវតែសម្រេចថា តើការយល់ឃើញរបស់អ្នកអង្កេតការដែលមិនលម្អៀងជាមួយនឹងការយល់ដឹងគ្រប់គ្រាន់លើកាលៈទេសៈនានាដើម្បីធ្វើការវិនិច្ឆ័យដោយសមហេតុផល ថា[ចៅក្រមដែលរងនូវការប្តឹងជំទាស់] នឹងមិនអាចធ្វើការវិនិច្ឆ័យដោយអនាគតិលើបញ្ហាទាំងឡាយដែលលេចចេញពីរឿងក្តីដែរ ឬទេ”[32]។

---

ត្រូវបានរកឃើញជាញឹកញាប់ថាលក្ខខណ្ឌតម្រូវនៃភាពមិនលម្អៀង ត្រូវបានរំលោភនៅករណីដែលចៅក្រមលម្អៀងជាក់ស្តែង ។ (លើកមកសំអាងសាលក្រមក្នុងរឿងក្តី Furundžija, កថាខណ្ឌ១៨១-១៨៨) ។ សូមមើលផងដែរឯកសារ E-63/5 សេចក្តីសម្រេចលើសំណើរបស់ អៀង ធីរិទ្ធ និង អៀង សារី សុំប្តឹងជំទាស់ចៅក្រម យូរ ឧត្តរា ពីគណៈកម្មាធិការពិសេស និងសំណើសុំឱ្យមានសវនាការសួរដេញដោលជាសាធារណៈ ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១១ ERN 00686820–00686826 (“សេចក្តីសម្រេចលើពាក្យប្តឹងជំទាស់ចៅក្រម យូរ ឧត្តរា”) នៅកថាខណ្ឌទី១១ ។

[30] សូមមើលអត្ថបទពេញនៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង នៅកថាខណ្ឌទី១១ (បានលើកសំអាងសេចក្តីសម្រេចក្នុងរឿងក្តី Furundžija, កថាខណ្ឌ១៨៩) ។ សូមមើលសេចក្តីសម្រេចលើពាក្យប្តឹងជំទាស់ចៅក្រម យូរ ឧត្តរា នៅកថាខណ្ឌទី១១ ។

[31] អត្ថបទពេញនៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង នៅកថាខណ្ឌទី១១ (បានលើកសំអាងសេចក្តីសម្រេចក្នុងរឿងក្តី Furundžija, កថាខណ្ឌ១៩០) ។ សូមមើលផងដែរសេចក្តីសម្រេចលើពាក្យប្តឹងជំទាស់ចៅក្រម យូរ ឧត្តរា នៅកថាខណ្ឌទី១១ ។

[32] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Karadžić*, IT-95-05/18-PT, ‘សេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រម Picard និងរបាយការណ៍ជូនអនុប្រធានតុលាការអនុលោមតាមវិធាន ១៥(ខ)(ii)’ ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០០៩ (‘សេចក្តីសម្រេចក្នុងរឿងក្តី Karadžić’), កថាខណ្ឌ១៨ (ការទាញហេតុសំអាងខាងក្នុងត្រូវបានលុប)។

៨. ភាគីដែលដាក់បណ្ដឹងជិតចិត្តមានបន្ទុកបង្ហាញភស្តុតាងឲ្យបានគ្រប់គ្រាន់ដែលអាចអាចជឿថា ចៅក្រមរងការប្ដឹងជិតចិត្ត មិនលម្អៀងជាអត្តនោម័ត ឬសត្យានុម័ត (អាចជាករណីនេះ)[33]។ ទាំងវិធានផ្ទៃក្នុង ឬក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មិនមានចែងពីការធ្វើសវនាការដេញដោល ផ្ទាល់មាត់លើពាក្យប្ដឹងជិតចិត្ត "តម្លាភាពនៃដំណើរការនីតិវិធី នឹងត្រូវបានធានាដោយ [...] ចំណាត់ថ្នាក់ការដាក់ឯកសារទាំងអស់ទាក់ទងនឹង [ពាក្យប្ដឹងជិតចិត្តទាំងអស់] ជាឯកសារ សាធារណៈ"[34] ។

៩. ដូចដែលបានលើកឡើងនាពេលថ្មីៗនេះដោយក្រុមមេធាវីការពារក្ដី អៀង សារី "នៅកម្រិត អន្តរជាតិ [...] ការខកខានរបស់ចៅក្រមក្នុងការបង្ហាញអង្គហេតុដែលជាតម្រុញនៃការជាប់ ពាក់ព័ន្ធមួយ ដែលអាចប៉ះពាល់ដល់ភាពមិនលម្អៀងរបស់គាត់ ត្រូវបានយល់ថាជាភស្តុតាង ដល់ការរកឃើញថាមានការកើតឡើងនូវកាលៈទេសៈដែល "អាចនាំឲ្យអ្នកអង្កេតមិនលម្អៀង ដែលត្រូវគេជូនដំណឹងយ៉ាងត្រឹមត្រូវ យល់ពីការលម្អៀងជាសន្យានុម័ត"[35] ។

## *គ. ការប្រាស្រ័យទាក់ទងជាមួយភាគីតែម្ខាង*

១០. ក្រមសីលធម៌ចៅក្រមហាមឃាត់មិនឲ្យមានការប្រាស្រ័យទាក់ទងភាគីតែម្ខាងរវាងចៅក្រម និងភាគីឡើយ ។ មាត្រា៩ នៃក្រមនេះបានចែងថា៖ "[...] ផ្អែកតាមគោលការណ៍ចំពោះមុខ ចៅក្រមមិនត្រូវប្រាស្រ័យទាក់ទងរវាងភាគីណាមួយនៅពេលដំណើរការនីតិវិធីដោយអវត្តមាន នៃភាគីម្ខាងទៀតឡើយលើកលែងតែច្បាប់អនុញ្ញាត ឬភាគីម្ខាងទៀតនោះយល់ព្រម" ។ មេធាវីការពារក្ដីសូមដាក់បញ្ចូលនូវសេចក្ដីសន្និដ្ឋានបន្ថែមទៀត ដែលបានលើកឡើងក្នុងកថាខណ្ឌទី ១៣ ដល់កថាខណ្ឌទី១៦ នៃសំណើរបស់លោក អៀង សារី ។

---

[33] សេចក្ដីសម្រេចក្នុងរឿងក្ដី Furundžija, កថាខណ្ឌ១៩៦ ។

[34] សេចក្ដីសម្រេចលើបណ្ដឹងជិតចិត្តចំពោះចៅក្រម និល ណុន នៅកថាខណ្ឌទី៣ ។ សូមមើលផងដែរអត្ថបទពេញនៃ សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង នៅកថាខណ្ឌទី៨ ។

[35] សំណើរបស់ អៀង សារី នៅកថាខណ្ឌទី៣ (សំអាងរឿងក្ដីរដ្ឋអាជ្ញា តទល់ជាមួយ *Karemera*, Case No ICTR-98-44-AR-15*bis*2, "មូលហេតុសម្រាប់ការសម្រេចលើបណ្ដឹងឧទ្ធរណ៍បន្ទាន់បង្ខំទាក់ទងនឹងការបន្តនីតិវិធីជាមួយចៅក្រម បម្រុង និងលើញត្តិរបស់ Nzirorera សុំផ្អាកការពិចារណាភស្តុតាងថ្មី" ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៤ នៅកថាខណ្ឌ ៦៧

១១. ដូចដែលបានកត់សម្គាល់កាលពីលើកមុន វិធាន ១៩ នៃវិធានផ្ទៃក្នុង ការបង្កើតគណៈកម្មាធិការតុលាការ បានចែងពីយន្តការណ៍សម្រាប់ដោះស្រាយការគាំទ្រផ្នែករដ្ឋបាល និងតុលាការនៅអវតក[36]។ គណៈកម្មាធិការតុលាការ "ត្រូវមានសមាសភាពចម្រុះដែលរួមមានចៅក្រមជាតិ និងចៅក្រមអន្តរជាតិ និងសហព្រះរាជអាជ្ញាទាំងពីរ និងប្រធាន និងអនុប្រធានការិយាល័យរដ្ឋបាល ក្នុងនាមអ្នកពិគ្រោះយោបល់"[37]។ បើតាមមេធាវីការពារក្តីដឹង ទាំងវិធានផ្ទៃក្នុង ឬបទបញ្ញត្តិដែលនៅជាធរមានដទៃទៀតនៅ អវតក មិនបានចែងពីការកិច្ចប្រជុំ "ក្នុងលក្ខណៈមិនផ្លូវការ ឬក្នុងលក្ខណៈមិនអចិន្ត្រៃយ៍ រវាងឬក្នុងចំណោមចៅក្រមអន្តរជាតិតែឯង សហព្រះរាជអាជ្ញាអន្តរជាតិតែឯង និង/ឬអ្នកសំរបសម្រួលរបស់ UNAKRT តែឯងឡើយ"[38]។

១២. វិធាននីតិវិធីក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិដទៃទៀត បង្កើតគណៈកម្មាធិការច្បាប់ពិសេសដែលដូចគ្នានឹងគណៈកម្មាធិការតុលាការដែរ ដើម្បីដោះស្រាយកិច្ចការរដ្ឋបាលផ្សេងៗរបស់តុលាការ។ នៅតុលាការ ICC ICTY និងICTR គណៈកម្មាធិការទាំងនេះត្រូវបានគេស្គាល់ថាជាក្រុមប្រឹក្សាសម្របសម្រួល។ គណៈកម្មាធិការទាំងនេះមានសមាសភាពប្រធានតុលាការព្រះរាជអាជ្ញា និងការិយាល័យរដ្ឋបាលតុលាការ ហើយជួបប្រជុំជាសាធារណៈ ស្របតាមលក្ខខណ្ឌតម្រូវដែលត្រូវបានកំណត់យ៉ាងច្បាស់លាស់[39] ។ ផ្អែកតាមព័ត៌មាន និងតាមការជឿក្របខណ្ឌច្បាប់នៃស្ថាប័នទាំងនេះ មិនបានចែងបន្ថែមពី "អង្គភាពរដ្ឋបាលក្រៅផ្លូវការមិនអចិន្ត្រៃយ៍ ដូចដែលបានលើកឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិឡើយ[40] ។

---

[36] វិធាន១៩ (២)។

[37] វិធាន១៩ (២)។

[38] លិខិតពីអ្នកសំរបសម្រួលរបស់ UNAKRT ទៅកាន់សហមេធាវីការពារក្តីលោក អៀង សារី ចុះថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១១។

[39] សូមមើលបទបញ្ជារបស់តុលាការ ICC, បទបញ្ជា៣ (ក្រុមប្រឹក្សាសំរបសម្រួល), វិធាននៃនីតិវិធី និងភស្តុតាងរបស់តុលាការ ICTY, វិធាន២៣ស្ទួន (ក្រុមប្រឹក្សាសំរបសម្រួល) និងវិធាននីតិវិធី និងភស្តុតាងរបស់តុលាការ ICTR, វិធាន២៣ស្ទួន (ក្រុមប្រឹក្សាសំរបសម្រួល)។

[40] សូមមើល Julia Wallace, កាសែត ឌឹ ឃែមបូឌា ដេលី , មេធាវីការពារក្តីនៅសាលាក្តីខ្មែរក្រហមចោទប្រកាន់ពីកិច្ចពិភាក្សារវាងភាគីតែម្ខាង, ចុះថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១១, ទំព័រទី១ (ដកស្រង់សំដីរបស់លោក Cayley៖ ឆ្លើយតបទៅនឹងការលើកឡើងរបស់ក្រុមមេធាវីការពារក្តីលោក អៀង សារី និងលោក នួន ជា, កិច្ចពិភាក្សាគ្រប់គ្រងផ្នែករដ្ឋបាលដូចកិច្ច

## IV. ឧទ្ទិស្សករណ៍

### ក. ពាក្យប្តឹងជិតចិត្តនេះដាក់ទាន់ពេលវេលា និងអាចទទួលយកបាន

១៣. ដូចដែលបានតម្រូវដោយវិធាន៣៤(៣) ពាក្យប្តឹងជិតចិត្តនេះបាន "បញ្ជាក់យ៉ាងច្បាស់អំពីមូលហេតុនៃការប្តឹងបណ្តឹងជិតចិត្ត និងបានផ្តល់នូវភស្តុតាងគាំទ្រ"។ ពាក្យប្តឹងជិតចិត្តនេះត្រូវបានដាក់យ៉ាងយកចិត្តទុកដាក់[41] ទៅអង្គជំនុំជម្រះសាលាដំបូង[42]ភ្លាមៗបន្ទាប់ពីមេធាវីការពារក្តីបានដឹងពីមូលហេតុដែលពាក់ព័ន្ធ[43]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងគួរតែទទួលយកពាក្យប្តឹងជិតចិត្តនេះ ។

### ខ. ចៅក្រម Cartwright ត្រូវតែ(ឬគួរតែ) លាឈប់ដោយរង់ចាំ សេចក្តីសម្រេចលើពាក្យប្តឹងជិតចិត្តនេះសិន

១៤. អនុលោមតាមវិធាន ៥៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចៅក្រម Cartwright ត្រូវតែចុះចេញពីតំណែងដោយរងចាំសេចក្តីសម្រេចលើពាក្យសុំជិតចិត្តបន្ទាន់នេះ[44] ។ ប្រសិនបើលោកស្រី Cartwright និងអង្គជំនុំជម្រះសាលាដំបូងនៅតែបន្តមិនគោរពនីតិវិធីដែលនៅជាធរមានរបស់ប្រទេសកម្ពុជា នោះយ៉ាងហោចណាស់ចៅក្រម Cartwright គួរតែលាឈប់ពីមុខតំណែងសិនស្របតាមវិធាន ៣៤(៥) ។ ទោះជាក្នុងករណីណាក៏ដោយ ចៅក្រម Cartwright ត្រូវតែបាន

---

ពិភាក្សាទាំងនេះបានកើតឡើងនៅតុលាការ ICC, ICTY និងICRT។ កិច្ចពិភាក្សាបែបនេះជារឿងធម្មតាទេ។ ប្រសិនបើកិច្ចពិភាក្សាបែបនេះមិនបានកើតឡើង ស្ថាប័នទាំងនោះ រួមទាំង អវតក ផងដែរ នឹងត្រូវធ្វើឲ្យស្ទះដំណើរការ។

[41] វិធាន៣៤(៤)(គ) (បណ្តឹងជិតចិត្តប្រឆាំងចៅក្រមនៅអង្គជំនុំជម្រះសាលាដំបូង, [...]...ទាក់ទងនឹងបញ្ហាដែលបានកើតឡើងក្នុង អំឡុងពេលជំនុំជម្រះ ត្រូវតែដាក់ជូន "មុនពេលធ្វើសេចក្តីសម្រេចចុងក្រោយលើសំណុំរឿងនេះ"។

[42] សូមមើលវិធាន៣៤ (៥) (បណ្តឹងជិតចិត្តចំពោះសហចៅក្រមស៊ើបអង្កេតត្រូវតែដាក់ជូនទៅអង្គបុរេជំនុំជម្រះ។ ក្នុងករណីផ្សេងទៀតពាក្យបណ្តឹងជិតចិត្តត្រូវដាក់ជូនទៅអង្គជំនុំជម្រះណាមួយដែលចៅក្រមនោះស្ថិតនៅ)។

[43] វិធាន៣៤(៣)។

[44] សូមមើលកថាខណ្ឌទី៥, ដូចគ្នា។

ដាក់ជំនួសដោយចៅក្រម Fenz ដោយសារតែគោលបំណងនៃបណ្ដឹងជំទាស់នេះ[45] ។

១៥. ចំណុចសំខាន់នៃបណ្ដឹងជំទាស់នេះគឺសាមញ្ញ។ ការចូលរួមរបស់ចៅក្រម Cartwright ក្នុងកិច្ចប្រជុំរវាងភាគីតែម្ខាង កិច្ចប្រជុំដែលហួសដែនអំណាច (*ultra vires*) និងកិច្ចប្រជុំមិនផ្លូវការជាមួយលោក Cayley និង/ឬលោក Rosandhaug (ហើយការខកខានរបស់គាត់ក្នុងការផ្ដល់ព័ត៌មានអំពីកិច្ចប្រជុំនេះ) បាននាំឱ្យមានការលេចចេញនូវភាពលម្អៀងដែលមិនអាចទទួលយកបាន ។ គេត្រូវតែបញ្ជាក់ឱ្យច្បាស់តាំងពីមុនដំបូងថាមេធាវីការពារក្ដីមិនបានលើកឡើងពីអត្ថិភាពនៃភាពលម្អៀង*ជាអត្តនោម័ត* របស់ចៅក្រម Cartwright ឡើយ។ ផ្ទុយទៅវិញ ផ្អែកតាមការវិភាគជាសន្សំនុម័ត ឥរិយាបទរបស់លោកស្រី Cartwright នឹងធ្វើឱ្យអ្នកអង្កេតការមិនលម្អៀងដែលទទួលបានព័ត៌មានពេញលេញ យល់ឃើញដោយសមហេតុផលអំពីការខ្វះអនាគតិរបស់ចៅក្រមរូបនេះ[46]។ ក្នុងករណីនេះ អ្នកអង្កេតការមិនលម្អៀង គឺជាបុគ្គលដែលទទួលបានព័ត៌មានពេញលេញដែលបានដឹងឮអំពី*ក្នុងចំណោមបញ្ហាដទៃទៀត* (i) យន្តការណ៍រដ្ឋបាលដែលមានស្រាប់នៅ អវតក និងនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិដៃទៃទៀត[47] (ii) ករណីកិច្ចរបស់ចៅក្រមនៅអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង00២[48] និង(iii) វិបត្តិផ្សេងៗនៃភាពសម្ងាត់ ពាក់ព័ន្ធតុលាការនេះចាប់តាំងពីវាបានបង្កើតឡើង[49]។

១៦. លិខិតរបស់លោក Rosandaug ទៅកាន់ភាគី[50] និងការអត្ថាធិប្បាយរបស់លោក Cayley ទៅ

---

[45] វិធាន៣៤(៦) (គួរកត់សម្គាល់ផងដែរថាប្រសិនបើចៅក្រមដែលកំពុងមានបញ្ហានោះ សម្រេចចិត្តលាឈប់ពីមុខតំណែង, ចៅក្រមនោះ អាចត្រូវជំនួសដោយចៅក្រមបម្រុងនៃអង្គជំនុំជម្រះនោះបានសម្រាប់តែករណីបណ្ដឹងជំទាស់នោះប៉ុណ្ណោះ)។ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា៥៥៩ (ក្នុងករណីបន្ទាន់ចៅក្រមនោះត្រូវបានជំនួសដោយចៅក្រមម្នាក់ទៀតដែលត្រូវចាត់តាំង ដោយប្រធានតុលាការរបស់ខ្លួន)។

[46] សាលក្រមក្នុងរឿងក្ដី Furundžija' , កថាខណ្ឌទី១៨៩។

[47] សូមមើលកថាខណ្ឌទី១១ ដល់១២, ដូចខាងលើ។

[48] សូមមើលកថាខណ្ឌទី៣, ដូចខាងលើ។

[49] សូមមើល ឧទាហរណ៍ ឯកសារ E-116/1។ (បណ្ដឹងឧទ្ធរណ៍បន្ទាន់ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងភាពត្រឹមត្រូវនៃការស៊ើបអង្កេត, ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១, ឯកសារ ERN 00746636-00746658។

[50] សំណើរបស់លោក អៀង សារី, កថាខណ្ឌទី៩។

កាន់កាសែតឌី ឃែមបូឌា ដេលី[51] បានបញ្ជាក់ថាកិច្ចពិភាក្សាទាំងនោះបានកើតឡើងក្នុងពេលមិនច្បាស់លាស់ ។ ដូចដែលបានកត់សម្គាល់ខាងលើ ការប្រជុំនេះមិនបានចែងក្នុងវិធាន១៩ ឬក្នុងបទបញ្ជារដ្ឋបាលដែលនៅជាធរមាន និងមានស្រាប់នៅ អវតក ឡើយ[52]។ ខណៈដែលភាគីទាំងអស់បានដឹងយ៉ាងច្បាស់អំពីគណៈកម្មាធិការរដ្ឋបាលតុលាការ[53] និងសកម្មភាពតាមផ្លូវច្បាប់របស់គណៈកម្មាធិការនេះ (ព្រមទាំងបទបញ្ញត្តិស្រដៀងគ្នាដែលមានស្រាប់នៅតុលាការព្រហ្មទណ្ឌអន្តរជាតិដទៃទៀត) មេធាវីការពារក្តីមិនដែលត្រូវបានគេជូនដំណឹងអំពីបញ្ហានេះទេ មិនថាឡើយយល់ព្រមចំពោះកិច្ចប្រជុំសម្ងាត់តាំងពីខែមេសា ឆ្នាំ២០១០ មកម្ល៉េះ ដែលចូលរួមតែ (បុគ្គលិកមិនមែនកម្ពុជា)[54]ប៉ុណ្ណោះ។ មកដល់ពេលនេះពុំមានមន្ត្រី អវតក ធ្វើការពន្យល់ថាតើហេតុអ្វី នៅពេលណា ដោយរបៀបណា និងអនុលោមតាមអំណាចផ្លូវច្បាប់អ្វីដែលបុគ្គលខាងលើនេះបានជួបប្រជុំគ្នាបែបនេះ ។ ដូច្នេះការចូលរួមរបស់ចៅក្រម Cartwright ក្នុងជំនួបទាំងនោះ គឺជាការរំលោភមាត្រា៩ នៃក្រមសីលធម៌ចៅក្រម[55]។

## ៣. ការខកខានរបស់ចៅក្រម Cartwright ក្នុងការផ្តល់ការបញ្ជាក់អះអាងដល់មេធាវីការពារក្តីបង្កើតបានជាការលេចឡើងពីភាពលម្អៀងជាសត្យានុម័ត

១៧. ខណៈដែលលោក Rosandhaug និងលោក Cayley បានលើកឡើងពីដែនកំណត់នៃព័ត៌មានទាក់ទងនឹងជំនួបទាំងនោះ ចៅក្រម Cartwright រក្សានៅភាពស្ងៀមស្ងាត់ ទោះបីជាមានសំណើបីផ្សេងពីគ្នាសុំឲ្យលាតត្រដាងអំពីអ្វីដែលបានកើតឡើងក្នុងកិច្ចប្រជុំទាំងនោះ ក៏ដោយ។ ដូចដែលបានកត់សម្គាល់ពីខាងដើម មេធាវីការពារក្តីមានមូលហេតុដែលត្រូវជឿថាមានអ្វី

---

[51] សូមមើលណើររបស់លោក អៀង សារី, កថាខណ្ឌទី១០។

[52] សូមមើលកថាខណ្ឌទី១១ ដូចខាងលើ។

[53] សូមមើលវិធាន១៩។

[54] សម្គាល់: អង្គភាពគាំពារការការពារក្តីមិនដែលទទួលបានព័ត៌មានអំពីកិច្ចពិភាក្សានេះទេ។

[55] សូមមើលកថាខណ្ឌទី១១០ដូចខាងលើ, សូមមើលសំណើរបស់ អៀង សារី កថាខណ្ឌ១៦, ២៨។

លើសពីបញ្ហារដ្ឋបាល និងការរៀបចំ ត្រូវបានគេលើកយកមកពិភាក្សា[56] ជាពិសេស (i)ការបន្តជ្រៀតជ្រែកពីសំណាក់រាជរដ្ឋាភិបាលកម្ពុជានៅ អវតក (ii) ឥទ្ធិពលនៃការជ្រៀតជ្រែកនេះទៅលើសំណុំរឿង ០០៣ និង០០៤ (iii) ឥទ្ធិពលនៃការជ្រៀតជ្រែកនេះទៅលើសំណុំរឿង ០០២ និង (iv) សំណើរបស់មេធាវីការពារក្តីសុំឱ្យមានការស៊ើបអង្កេតដោយឯករាជ្យទៅលើការជ្រៀតជ្រែកបែបនេះ[57]។

១៨. ច្បាស់ណាស់ចៅក្រម Cartwright មានកាតព្វកិច្ចត្រូវបញ្ជាក់ឱ្យបានច្បាស់ថាតើទទួលស្គាល់ ឬបដិសេធព័ត៌មាននេះ ។ បើពិនិត្យមើលទៅលើលក្ខណៈមិនសមស្របជាសន្ទានុម័តនៃកិច្ចពិភាក្សានេះ និងតថភាពនយោបាយនៅតុលាការនេះ ការខកខានរបស់លោកស្រី Cartwright អាចនាំឱ្យអ្នកអង្កេតការដែលមិនលម្អៀង ដែលទទួលបានព័ត៌មានពេញលេញយល់ឃើញដោយធាតុផ្សំសត្យានុម័តថាលោកស្រី Cartwright មានភាពលម្អៀង[58] ។ ពិតណាស់អ្នកអង្កេតការមិនលម្អៀងនឹងកត់សម្គាល់ថាចំណុច ៤ ដែលលើកឡើងពីខាងលើ គឺជាប្រធានបទនៃការត្រួតពិនិត្យយ៉ាងតឹងរឹងដោយអ្នកអង្កេតការមិនលម្អៀងទាំងអស់ និងយ៉ាងហោចណាស់ដោយចៅក្រមអន្តរជាតិពីរនាក់នៅតុលាការនេះផងដែរ។ ពិតណាស់ ដូចដែលបានលើកឡើងពីខាងដើម សំណើដែលបានយោងក្នុងចំណុចទី៤ គឺនៅទើត្រឹមអង្គជំនុំជម្រះសាលាដំបូង

[56] សម្គាល់: សូម្បីតែអ្វីដែលសហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងទៅកាន់លោក Michiel Pestman, មេធាវីការពារក្តី ទទួលបានព័ត៌មាននេះពីប្រភពដែលគួរឱ្យទុកចិត្តបានមួយដែលសុំមិនបញ្ចេញឈ្មោះ។ ព័ត៌មានភាគច្រើនដែលបានមកពីប្រភពនេះ ត្រូវបានបញ្ជាក់គាំទ្រដោយឯករាជ្យ ហើយព័ត៌មួយចំនួនក៏បានទទួលស្គាល់ដោយលោក Rosandhaug និងលោក Cayley ខ្លួនឯងផ្ទាល់ផងដែរ។

[57] សូមមើលសំណើរបស់ នួន ជា កថាខណ្ឌទី៧ ។ កត់សម្គាល់៖ សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយតុលាការឯករាជ្យ គឺជាសិទ្ធិជាមូលដ្ឋានដូចដែលអ្វីដែលមេធាវីការពារក្តីបានអះអាងជាបន្តបន្ទាប់ ចាប់តាំងពីការចាប់ផ្តើមសំណុំរឿង ០០២ មកម្លេះ ។

[58] សំណើរបស់លោក អៀង សារី កថាខណ្ឌទី៣៣ (ដកស្រង់រឿងក្តីរដ្ឋអាជ្ញាតទល់នឹង Karmera, សំណុំរឿង ICTR-98-44-AR 15*bis*.2, មូលហេតុនៃសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំទាក់ទងនឹងការបន្តដំណើរការនីតិវិធីដោយចៅក្រមជំនួស និងលើញាតិរបស់ Nziorera សុំការអនុញ្ញាតពិចារណាសម្ភារៈថ្មី, ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៤ កថាខណ្ឌទី៦៧)។

នៅពេលតំណាលគ្នាដែលកិច្ចពិភាក្សាទាំងនេះបានកើតឡើង[59]។

១៩. មានការលើកឡើងថាមូលហេតុជម្រុញដែលនាំឲ្យមានកិច្ចពិភាក្សារវាងភាគីតែម្ខាងនេះ គឺផ្ដើមចេញពីជំនួបនៅទីក្រុងញ៉ូយកជាមួយនឹងលោកស្រី Patricia 0Brien អគ្គលេខាធិការរងអង្គការសហប្រជាជាតិទទួលបន្ទុកកិច្ចការច្បាប់ ។ គោលបំណង គឺបង្កើនការប្រាស្រ័យទាក់ទងរវាងផ្នែកនានារបស់អង្គការសហប្រជាជាតិនៅ អវតក និងទីស្នាក់ការកណ្ដាលរបស់អង្គការសហប្រជាជាតិ នេះបើតាមលោក Rosandhaug ប្រាប់មេធាវីការពារក្ដី[60]"។ ខណៈដែលករណីនេះជាដើមចមនៃបញ្ហានេះ[61] ការជម្រុញរបស់លោកស្រី Patricia 0Brien មិនជាប់ពាក់ព័ន្ធនឹងបណ្ដឹងជិតចិត្តបន្ទាន់នេះឡើយ ។ ខណៈដែលកិច្ចពិភាក្សាសម្ងាត់នេះ ប្រហែលជាត្រូវបានគេធ្វើឡើងដោយមានគោលបំណងជាក់លាក់បំផុត[62] ប្រការដែលថាកិច្ចប្រជុំនេះត្រូវបានធ្វើឡើងដោយរំលោភយ៉ាងច្បាស់ទៅនឹង CJE (ដោយមិនបានសួរយោបល់ មិនថាឡើយទទួលការយល់ព្រមពីមេធាវីការពារក្ដី) នៅពេលដែលមានការបែងចែករវាងអន្តរជាតិ/កម្ពុជានៅ អវតក ។

---

[59] សូមមើលកថាខណ្ឌទី២, ដូចខាងលើ។

[60] Julia Wallace កាសែត ខឺ ឃែមបូឌា ដេលី មន្ត្រីរដ្ឋបាលនៅ អវតក ថ្លែងថាកិច្ចប្រជុំនេះជាកិច្ចប្រជុំមិនអចិន្ត្រៃយ៍, ចុះថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១១ ទំព័រទី១៩។

[61] សូមមើលខាងលើ (Martin Nesirsky) អ្នកនាំពាក្យរបស់ការិយាល័យច្បាប់អង្គការសហប្រជាជាតិ បដិសេធមិនព្រមធ្វើអត្ថាធិប្បាយលើបញ្ហាថាតើហេតុអ្វីបានជាលោកស្រី Patricia 0 Brien ពិតជាបានផ្ដល់អនុសាសន៍បែបនេះ ។

[62] ដូចគ្នាខាងលើ (ដកស្រង់សំដីរបស់ Clair Duffy, អ្នកឃ្លាំមើលតុលាការរបស់អង្គការផ្តួចផ្តើមយុត្តិធម៌សង្គមបើកទូលាយ អ្នកស្រីបានសរសេរតាមសារអេឡិចត្រូនិចមួយថា៖ "ខ្ញុំចាំបាច់ត្រូវតែនិយាយថាខ្ញុំអាណិតភាគីទាំងសងខាងលើបញ្ហានេះ ។ "ខ្ញុំគិតថាវាមានសារៈសំខាន់ និងសមហេតុផលជាទីបំផុតក្នុងការដែលមេដឹកនាំខាងភាគីអន្តរជាតិក្នុងតុលាការនេះជួបពិភាក្សាពីបញ្ហានានាទាក់ទងនឹងការរៀបចំជាបន្តបន្ទាប់នៅក្នុងតុលាការនេះ ហើយខ្ញុំប្រាកដណាស់ថាកិច្ចពិភាក្សានេះត្រូវបានធ្វើឡើងដោយមានគោលបំណងច្បាស់លាស់ និងប្រកបដោយសុច្ចរិតភាព"។ ប៉ុន្តែមេធាវីការពារក្ដីក៏មានសិទ្ធិស្នើសុំឲ្យមាន តម្លាភាពជាងនេះលើបញ្ហាប្រភេទនេះ ដោយសារតែតុលាការនេះជាទូទៅត្រូវបានគេមើលឃើញថាខ្វះតម្លាភាព ជាពិសេស ពាក់ព័ន្ធតែក្នុងសំណុំរឿង 00៣ និង 00៤)។

## VI សេចក្តីសន្និដ្ឋាន

២០. អាស្រ័យហេតុនេះ មេធាវីការពារក្តីសូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង៖

ក. ទទួលយកបណ្តឹងជំទាស់ចិត្តនេះ ។

ខ. ជម្រុញឲ្យចៅក្រម Cartwright លាឈប់ពីមុខតំណែង អនុលោមមាត្រា ៥៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឬយ៉ាងហោចណាស់លាឈប់ពីមុខតំណែងដោយស្ម័គ្រចិត្ត ស្របតាមវិធាន ៣៤(៥) ដោយរង់ចាំសេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្តបន្ទាន់នេះ ហើយតែងតាំងចៅក្រម Fenz ដើម្បីជំនួសកន្លែងទំនេរនេះ ។

គ. បង្គាប់ឲ្យមានការលាលែងជាបន្ទាន់ និងជាអចិន្ត្រៃយ៍នៃចៅក្រម Cartwright ពីចូលរួមក្នុងដំណើរការនីតិវិធីបន្ថែមទៀតប្រឆាំងនិងលោក នួន ជា ក្នុងសំណុំរឿង ០០២ ។

ដោយយោងទៅលើលក្ខណៈនៃបណ្តឹងជំទាស់ចិត្តបន្ទាន់នេះ មេធាវីការពារក្តីសូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុកបណ្តឹងនេះជាបញ្ហាបន្ទាន់។

**សហមេធាវីការពារក្តីលោក នួន ជា**





**សុន អរុណ** Michel PESTMAN & Victor KOPPE